Empowered lives.
Resilient nations.

# ព្រឹត្តិបត្រព័ត៌មាន

លេខ ៤៦
ខែ មិថុនា ឆ្នាំ ២០១៥

*យូអិនឌីភី ធ្វើដៃគូជាមួយប្រជាជនគ្រប់ស្រទាប់សង្គមក្នុងការជួយប្រជាជាតិឲ្យមានភាពស្វិតស្វាញទប់ទល់នឹងវិបត្តិ ជំរុញ និងរក្សាចីរភាពកំណើន សំដៅលើកស្ទួយគុណភាពនៃជីវភាពសម្រាប់ទាំងអស់គ្នា។ យើងមានវត្តមានក្នុងប្រទេសនិងដែនដីជាង ១៧០ ហើយយើងប្រើប្រាស់ទស្សនវិស័យសកល និងក្នុងស្រុក ដើម្បីជួយប្រជាជន និងប្រជាជាតិកសាងជីវភាពឲ្យបានកាន់តែប្រសើរ និងរឹងមាំថែមទៀត។*

## ស្ត្រីទទួលបានរង្វាន់កសិករគំរូនៅកម្ពុជា



Photo: UNDP Cambodia

*កសិករ រុន ម៉ាច ដែលជាកសិករគំរូក្នុងការធ្វើកសិកម្មចម្រុះ ទទួលបានរង្វាន់ទី៥ នៅក្នុងការប្រឡងទូទាំងប្រទេសក្នុងការធ្វើកសិកម្មចម្រុះលើកទី៦។*

ស្ត្រីខ្មែរ ដែលធ្លាប់តែពឹងផ្អែកលើការងារមិនប្រក្រតីសម្រាប់ការរស់នៅ បានស្ថិតក្នុងចំណោមអ្នកឈ្នះប្រាំនាក់នៅក្នុងការធ្វើកសិកម្ម ដែលរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

នៅក្នុងពិធីមួយកាលពីថ្ងៃព្រហស្បតិ៍ ទី ១៩ ខែមីនា ក្រសួងនេះបានប្រកាសថា អ្នកស្រី រុន ម៉ាច អាយុ ៤៨ឆ្នាំ គឺជាបេក្ខជនទីប្រាំដែលឈ្នះនៅក្នុងការប្រកួតប្រជែងធ្វើ "ប្រព័ន្ធកសិកម្មចម្រុះ" និងបានផ្តល់ឲ្យគាត់នូវកញ្ចប់រង្វាន់មួយ ដែលរួមមាន ម៉ាស៊ីនបូមទឹកមួយគ្រឿង ប្រាក់ចំនួន ១៥០ដុល្លាអាមេរិក និងវិញ្ញាបនបត្រមួយផងដែរ។

អ្នកស្រីម៉ាច មកពីភូមិធម្មជាតិ ក្នុងខេត្តព្រះវិហារ ដែលស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា។ អ្នកស្រីបានពោលថា "នេះគឺជាលើកដំបូងរបស់ខ្ញុំដែលបានធ្វើបទបង្ហាញមួយ នៅចំពោះមុខអ្នកចូលរួមជាច្រើនរយនាក់។ ខ្ញុំញាប់ញ័រ ប៉ុន្តែខ្ញុំបានព្យាយាមជាទីបំផុត

*តទៅទំព័រទី ២*

## មាតិកា

សិស្សកម្ពុជាទទួលបានបទពិសោធន៍ជាក់ស្តែងអំពីការដាំបន្លែ ដែលបន្សាំនឹងអាកាសធាតុ ......៣
គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុមួយផ្តល់ផលបីយ៉ាង ......................................៤
កម្ពុជាត្រូវចាប់យកភាគលាភប្រជាសាស្ត្រ ដើម្បីការអភិវឌ្ឍន៍ ...................................... ៥
សកម្មភាពសម្អាតមីនធ្វើឲ្យក្តីសង្ឃឹមទទួលបានការសិក្សារបស់ក្មេងមានជីវិតឡើងវិញ ............. ៦

## ប្រជាជនក្នុងភូមិមួយនៅកម្ពុជាបោះជំហានបែបសហគ្រិនភាព ក្នុងការដោះស្រាយបញ្ហាខ្វះទឹក



Photo: Chansok Lay/UNDP Cambodia

*ប្រតិភូប្រទេសស៊ុយ អែដ និងយូអិនឌីភី ចុះមើលសកម្មភាពពង្រីកអាងស្តុកទឹង នៅក្នុងភូមិ ក្រាំង សេរី ស្ថិតក្នុងខេត្តកំពង់ស្ពឺ។ ក្រោយការពង្រីករួច អាងនេះនឹងអាចស្តុកទឹកបានរហូតដល់ ៦០.០០០ ម៉ែត្រគូប។*

**កំពង់ស្ពឺ –** ដំបូងឡើយគាត់បានគិត ឥឡូវនេះគឺគាត់កំពុងតែអនុវត្ត។ វាគឺជាគម្រោងការចែកចាយទឹក ដែលលោក ឡុង ធីម កំពុងមើលការខុសត្រូវនៅក្នុងភូមិក្រាំង សេរី ក្នុងខេត្តកំពង់ស្ពឺ។ នៅពេលដែលគម្រោងនេះ បញ្ចប់នៅចុងឆ្នាំ២០១៥ ប្រជាជនជាង៥០០គ្រួសារនៅភូមិជិតខាងនឹងមានទឹកប្រើប្រាស់ដល់ចង្ក្រានបាយរបស់ ពួកគេមួយឆ្នាំពេញ។

លោក ឡុង ធីម ដែលជាប្រធានគណៈកម្មការគ្រប់គ្រងអាងទឹកក្នុងភូមិក្រាំង សេរី បានពោលថា "យើងបានសម្រេចការងារពង្រីកអាងស្តុកទឹកនេះប្រហែល ៤០ ភាគរយហើយ។ នៅក្នុងពេលប្រហែលពីរទៅបីអាទិត្យទៀត យើងនឹងមានអាងទឹកដែលមានទំហំធំជាងមុន។ លោកបានពោលយ៉ាងដូច្នេះនៅក្នុងពេលទស្សនកិច្ចរបស់ប្រតិភូមកពីប្រទេសស៊ុយអែដ កាលពីចុងខែឧសភា។

ដើម្បីឆ្លើយតបតម្រូវការថ្មីៗបន្ថែមទៀត លោក ឡុង ធីម បានធ្វើសេចក្តីសម្រេចចិត្តបែបសហគ្រិនភាព ដោយ ខ្ចីប្រាក់ ១០.០០០ដុល្លារអាមេរិក ពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ បន្ថែមលើមូលនិធិរួមរបស់សហគមន៍ ដើម្បីអនុវត្តគម្រោងមួយនេះ។ ស្រដៀងគ្នាទៅនឹងភូមិដ៏ទៃទៀតនៅក្នុងប្រទេស សម្រាប់ភូមិមួយដែលមិនបានទទួលនូវមូលនិធិអភិវឌ្ឍន៍ផ្ទាល់ពីរដ្ឋាភិបាល ការសម្រេចចិត្តបែបនេះគឺជាការបោះជំហានដ៏ប្រថុយប្រថានមួយ ប៉ុន្តែវាក៏ជាអ្វី ដែលលោក ឡុង ធីម និងសហគមន៍របស់គាត់បានគិតថាសមប្រកបទៅនឹងការទទួលបានសម្រាប់អ្នកទាំងអស់គ្នា ផងដែរ។

តាមគម្រោងដែលចាប់ពន្លកកាលពីពីរឆ្នាំមុន អាងស្តុកទឹកនៅក្នុងភូមិក្រាំង សេរី ត្រូវបានកំពុងពង្រីកដើម្បីផ្ទុកទឹកឲ្យបានរហូតដល់ ៦០.០០០ ម៉ែត្រគូប ដែលទំហំនេះគឺធំជាងលើស២ដងធៀបនឹងទំហំផ្ទុករបស់អាងនៅពេលសាងសង់រួចដំបូង។ ប្រព័ន្ធបំពង់ចែកចាយទឹកតភ្ជាប់ពីអាងស្តុកទឹក ក៏នឹងត្រូវបានតបន្ថែមនៅចុងឆ្នាំនេះសម្រាប់អតិថិជនថ្មីៗ។ ផ្ទះនីមួយៗត្រូវបង់ ២.០០០ រៀលក្នុងការប្រើប្រាស់ទឹក ១ម៉ែត្រគូប ដែលតម្លៃនេះគឺស្មើនឹងមួយភាគប្រាំនៃតម្លៃដែលប្រជាជនទិញទឹកពីឈ្មួញដឹកទឹកលក់តែប៉ុណ្ណោះ។

កាលពីមុន សម្រាប់អ្នកភូមិក្រាំង សេរី ដែលស្ថិតនៅប្រមាណ៦០គីឡូម៉ែត្រភាគនិរតីទីក្រុងភ្នំពេញ កង្វះខាតទឹកគឺមិនមែនជារឿងចម្លែកទេ។

អ្នកស្រី ប្រាក់ ឃុន បានរម្លឹកពីភាពលំបាកកាលពីអតីតកាលថា "មុនពេលមានអាងទឹកនេះ គ្រួសារខ្ញុំជួបបញ្ហាគ្រប់បែបយ៉ាង។ អំពើហិង្សាក្នុងគ្រួសារ អសន្តិសុខស្បៀង ជំងឺផ្សេងៗ ហើយកូនក៏មិនបានទៅរៀនដែរ ដោយសារពួកគេត្រូវជួយរកទឹកមកប្រើប្រាស់។"

បញ្ហាកង្វះទឹកនៅភូមិក្រាំង សេរី ត្រូវបានដោះស្រាយ បន្ទាប់ពីគម្រោងគ្រប់គ្រងទឹកនៅទីនោះត្រូវបានបញ្ចប់នៅ

*តទៅទំព័រទី ២*

## ប្រជាជនក្នុងភូមិមួយនៅកម្ពុជាបោះជំហានបែប...

*តមកពីទំព័រទី ១*

ឆ្នាំ២០១២។ ជាកិច្ចឆ្លើយតបទៅនឹងស្ថានភាពខ្វះខាតទឹកនៅពេលនោះ ប្រទេសស៊ុយអែដ តាមរយៈកម្មវិធីបន្សាំការប្រែប្រួលអាកាសធាតុនៅតាមសហគមន៍នៅកម្ពុជា (CCBAP) របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) បានជួយជាថវិកាដើម្បីជីកអាងដើម្បីប្រមូលទឹកភ្លៀងដែលហូរចុះមកពីភ្នំនៅជុំវិញនៅក្នុងរដូវវស្សា។ អាងស្តុកទឹក នោះអាចស្តុកទឹកបានប្រមាណ ២៥.០០០ ម៉ែត្រគូប និងប្រព័ន្ធបំពង់ចែកចាយទឹកក៏ត្រូវបានតភ្ជាប់ពីអាងស្តុកទឹកទៅកាន់ផ្ទះទាំង ៧០ខ្នង នៅក្នុងភូមិដែលធ្វើឲ្យពួកគេមានទឹកប្រើប្រាស់ពេញមួយឆ្នាំ។

បន្ទាប់ពីទទួលបានទឹកប្រើប្រាស់គ្រប់គ្រាន់ ប្រជាជននៅក្នុងភូមិក៏បាននាំគ្នាបង្កើនប្រភពប្រាក់ចំណូលតាមរយៈការដាំបន្លែ និងការចិញ្ចឹមសត្វជ្រូក និងមាន់ជាដើម។ បង្គន់ប្រើទឹក ដែលពីមុនគឺជាប្រណិតភាពសម្រាប់ពួកគេក៏ត្រូវបានសាងសង់ឡើងស្ទើរគ្រប់ផ្ទះ ដើម្បីបង្កើនអនាម័យ និងកាត់បន្ថយជំងឺឆ្លងតាមទឹក ដូចជា រោគរាករូសក្នុងចំណោមកុមារផងដែរ ។

ការមានប្រព័ន្ធបំពង់ចែកចាយទឹក បានធ្វើឲ្យអ្នកភូមិជិតខាងមានចិត្តចង់បានផងដែរ ដែលនាំឲ្យអ្នកភូមិក្រាំងសេរី ឯកភាពគ្នាជួយអ្នកភូមិជិតខាងរបស់។

លោក ឡុង ធីម បានពោលថា "ប្រសិនបើយើងពង្រីកប្រព័ន្ធបំពង់ចែកចាយទឹក យើងអាចជួយអ្នកភូមិផ្សេងទៀតផង ហើយយើងក៏អាចរកប្រាក់ចំណូលសម្រាប់សហគមន៍ផង។ ដូច្នេះហើយ ពួកយើងក៏ឯកភាពគ្នាក្នុងសហគមន៍ដើម្បី ពង្រីកអាងស្តុកទឹក និងបន្តបំពង់ចែកចាយទឹកទៅកាន់ភូមិជិតខាងបន្តរទៀត។"



Photo: Chansok Lay/UNDP Cambodia

*សមាជិកសហគមន៍ធ្វើបទបង្ហាញអំពីផលប្រយោជន៍របស់អាងស្តុកទឹក និងគម្រោងផែនការបច្ចុប្បន្ន និងអនាគតដល់ប្រតិភូមកពីប្រទេសស៊ុយអែដ និងយូអិនឌីភី ។*

ប្រសិនអ្វីៗដំណើរការដូចការគ្រោងទុក ប្រាក់កម្ចីនឹងត្រូវបានសងរួចរាល់ក្នុងរយៈពេល២ឆ្នាំយ៉ាងយូរ ដោយប្រើប្រាស់ចំណូលមកពីកម្រៃសេវានានាដែលផ្តល់ឲ្យអតិថិជនថ្មីៗទាំងនោះ។

នៅក្នុងដំណើរទស្សនកិច្ចទៅកាន់ភូមិក្រាំង សេរីនាពេលថ្មីៗនេះ អ្នកស្រី អាសា ហេដេន ដែលដឹកនាំប្រតិភូ មកពីទីក្រុងស្តុកហូម នៃប្រទេសស៊ុយអែដ បានពោលថា "ខ្ញុំស្ញើចសរសើរសហគមន៍នេះណាស់។ ពួកគេបានប្រើប្រាស់ទឹកប្រាក់តិចតួចដែល យូអិនឌីភី និងស៊ីដា បានគាំទ្រ និងបានពង្រីកគម្រោងនេះ។ ខ្ញុំគិតថាពួកគេមានស្មារតីជាសហគ្រិន និងមានការទទួលខុសត្រូវលើសហគមន៍នេះទាំងមូល។"

លោកស្រី ហេដេន បានបន្តពោលថា "វាពិតជាល្អណាស់ដែលបានឃើញគម្រោងបែបនេះ។ វាមានលក្ខណៈស្របគ្នាច្រើនជាមួយនឹងគោលដៅជំនួយរបស់ប្រទេសស៊ុយអែដសម្រាប់កម្ពុជា ដូចជាការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ សិទ្ធិមនុស្ស ការជម្រុញការចូលរួមរបស់ស្ត្រី សមភាពយេនឌ័រ និងមានការគិតគូរអំពីទំនាស់ ហើយគម្រោងនេះក៏ពាក់ព័ន្ធជាមួយកំណើនសេដ្ឋកិច្ចសម្រាប់កាត់បន្ថយភាពក្រីក្រផងដែរ។ ពិតណាស់នេះជាគម្រោងជោគជ័យមួយ។"

លោក ណាប៉ូឡេអុង ណាវ៉ារ៉ូ នាយករងការិយាល័យយូអិនឌីភីប្រចាំនៅកម្ពុជា ក៏បានឆ្លើយតបទៅនឹងពាក្យសម្តីដឹងគុណរបស់អ្នកភូមិ ចំពោះជំនួយរបស់ប្រទេសស៊ុយអែដ និងយូអិនឌីភីផងដែរ។

នៅក្នុងជំនួបជាមួយសហគមន៍ លោកបានពោលថា "អ្នកទាំងអស់គ្នាបានអរគុណយើងដែលបានផ្តល់មូលនិធិគាំទ្រដល់អ្នករាល់គ្នា។ ប៉ុន្តែប្រការសំខាន់ជាងនេះគឺ អ្នកទាំងអស់គ្នាទេដែលបានធ្វើឲ្យការប្រែប្រួលទាំងនេះកើតឡើង។ ដូច្នេះអ្នកត្រូវថ្លែងអំណរគុណចំពោះខ្លួនឯង។"

នៅពេលចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ២០១២ សហគមន៍នេះបានទទួលជំនួយជាទឹកប្រាក់ ៤៩.៨៣២ ដុល្លារអាមេរិក ពីគម្រោង CCBAP ក្នុងចំណោមប្រាក់ចំណាយសរុប ៦០.២៥៧ ដុល្លារអាមេរិក សម្រាប់សាងសង់អាងទឹក និងប្រព័ន្ធចែកចាយទឹក។ នៅចុងឆ្នាំ ២០១៥នេះ គម្រោងដែលកាលពីចាប់ផ្តើមមានគោលដៅដោះស្រាយបញ្ហាទឹកសម្រាប់តែប្រជាជន ៧០គ្រួសារ នៅក្នុងភូមិក្រាំងសេរី នឹងផ្តល់ដំណោះស្រាយ ចំពោះបញ្ហាស្រដៀងគ្នានេះសម្រាប់ប្រជាជនច្រើនជាង ៥០០គ្រួសារនៅក្នុងភូមិចំនួនប្រាំ។

---

## ស្ត្រីទទួលបានរង្វាន់កសិករគំរូ...

*តមកពីទំព័រទី ១*

ហើយខ្ញុំរីករាយណាស់ជាមួយអ្វីដែលខ្ញុំបានទទួល។"

ស្ត្រីម៉េម៉ាយ ដែលមានកូនពីរនាក់ ស្ថិតក្នុងចំណោមអ្នកភូមិចំនួន ១៣.៥៨១ នាក់ ដែលកំពុងទទួលផលពីគម្រោងមួយ ដែលទទួលមូលនិធិពីប្រទេសកាណាដា មូលនិធិបរិស្ថានពិភពលោក និងយូអិនឌីភី។ គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្មក្នុងប្រទេសកម្ពុជា ត្រូវបានអនុវត្តដោយអង្គភាពគ្រប់គ្រងគម្រោងនៃក្រសួងកសិកម្ម។ ក្រៅពីជួយដោះស្រាយបញ្ហាខ្វះទឹក គម្រោងនេះក៏បណ្តុះបណ្តាលអ្នកភូមិអំពីបច្ចេកទេសក្នុងការបង្កើនមុខដំណាំ ដើម្បីបង្កើនសន្តិសុខស្បៀង និងប្រាក់ចំណូល និងបង្កើនភាពធន់ចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុផងដែរ។

កសិករសរុបចំនួន ២១០គ្រួសារ បានចូលរួមប្រឡងប្រណាំងក្នុងសន្និបាតកសិករលើកទី ៦ ដែលការប្រកួតបានចាប់ផ្តើមកាលពីថ្ងៃទី ១០ ខែកុម្ភៈ និងបានបញ្ចប់នៅថ្ងៃទី ១៩ ខែមីនា។ នៅក្នុងពេលប្រកួតពួកគេបានសាកល្បងចំណេះដឹងបច្ចេកទេសរបស់ខ្លួននិងជំនាញអនុវត្តផ្ទាល់លើប្រធានបទនានា ដូចជា ការបង្កើនពូជដំណាំ ការស្រោចស្រពស្រូវស្រែ ការចិញ្ចឹមសត្វ និងត្រីហើយអ្វីដែលសំខាន់ផងដែរនោះគឺ ការគ្រប់គ្រងព្រៃសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។



Photo: Chansok Lay/UNDP Cambodia

*អ្នកស្រី រុន ម៉ាច កំពុងថែទាំបន្លែដែលគាត់បានដាំនៅក្នុងទីធ្លាផ្ទះរបស់គាត់ នៅភូមិធម្មជាតិ ខេត្តព្រះវិហារ។*

ទោះបីនេះជារង្វាន់ចុងក្រោយក្នុងចំណោមអ្នកទាំងប្រាំក៏ដោយ រង្វាន់នេះមានសារៈសំខាន់ណាស់សម្រាប់អ្នកស្រីម៉ាចដែលកាលពីមុនបានពឹងផ្អែកតែលើការធ្វើការនៅក្នុងកសិដ្ឋានរបស់អ្នកដទៃទៀតក្នុងភូមិ ដើម្បីទទួលបានថ្លៃឈ្នួលបន្តិចបន្តួច សម្រាប់ទ្រទ្រង់ជីវភាពខ្លួនឯង និងកូនស្រីទាំងពីរនាក់។ ប៉ុន្តែ ជីវិតបានប្រែជាប្រសើរឡើងវិញ នៅពេលដែលគម្រោងនេះបានមកដល់ភូមិរបស់អ្នកស្រីនៅក្នុងឆ្នាំ២០១៣ ជាមួយកញ្ចប់គាំទ្រដល់របរចិញ្ចឹមជីវិតដែលរួមមាន ម៉ាស៊ីនបូមទឹកដើរដោយថាមពលព្រះអាទិត្យមួយឈុត និងបច្ចេកទេសបង្កើនមុខដំណាំ។

អ្នកស្រីម៉ាច បានពោលថា "ខ្ញុំនឹងមិនអង្គុយចាំឲ្យគេប្រាប់ថាខ្ញុំគួរធ្វើនោះឡើយ។ ខ្ញុំនឹងបន្តធ្វើការយ៉ាងសកម្ម ហើយតាមរយៈកិច្ចការនេះ ខ្ញុំសង្ឃឹមថានឹងអាចរកប្រាក់បានកាន់តែច្រើនបន្ថែមទៀត។ ហើយការខិតខំនេះ គឺមិនមែនដើម្បីបំពេញចិត្តអ្នកណាម្នាក់ឡើយ ប៉ុន្តែគឺសម្រាប់ខ្លួនខ្ញុំ និងគ្រួសារខ្ញុំផ្ទាល់"

អ្នកស្រីពោលថា នៅឆ្នាំ ២០១៤ គាត់រកប្រាក់បាន ១២,៤២លានរៀល (៣.១០៥ ដុល្លាអាមេរិក) ពីការលក់ផលិតផលដែលគាត់បានដាំនៅជុំវិញផ្ទះរបស់គាត់។ គាត់បានបន្ថែមថា តាមរយៈការបង្កើនចំណែកដីសម្រាប់ដាំដំណាំ និងការចិញ្ចឹមសត្វ គាត់រំពឹងថាប្រាក់ចំណូលរបស់គាត់នឹងកើនឡើងប្រមាណ ៣០ភាគរយ បន្ថែមទៀតនៅក្នុងឆ្នាំនេះ។

អ្នកស្រីម៉ាច បានពោលនៅក្រោយការទទួលរង្វាន់កាលពីថ្ងៃព្រហស្បតិ៍ថា "នៅពេលត្រឡប់ដល់ផ្ទះវិញ ខ្ញុំនឹងបន្តចែករម្លែកបទពិសោធន៍ដល់អ្នកភូមិដទៃទៀត ជាពិសេសអំពីការបង្កើនគុណភាពដី តាមរយៈការដាំបន្លែនានាមួយចំនួនផងដែរ។"

អ្នកឈ្នះចំនួនបួននាក់ផ្សេងទៀត ដែលបានទទួលរង្វាន់ច្រើនជាង គឺកសិករមកពីខេត្តកំពង់ឆ្នាំង សៀមរាប ស្វាយរៀង និងបាត់ដំបង។

# សិស្សកម្ពុជាទទួលបានបទពិសោធន៍ជាក់ស្តែងអំពីការដាំបន្លែ ដែលបន្សាំនឹងអាកាសធាតុ

ត្រឹមក្នុងរយៈពេលមួយខែនៅក្រោយពេលពូជបន្លែត្រូវបានផ្តល់ទៅឲ្យនាយកសាលា និងគ្រូបង្រៀន ឥឡូវនេះទីធ្លាក្នុងសាលាបឋមសិក្សាគោកស្រឡៅមានទេសភាពស្រស់បំព្រង និងពណ៌បៃតងខ្ចី។ ជាមួយបាយកញ្ចប់ពីផ្ទះ សិស្ស និងគ្រូខ្លះ មកសាលារៀនតាំងពីព្រលឹម ដើម្បីស្រស់ស្រូបអាហារពេលព្រឹកជាមួយបន្លែដែលពួកគេដាំនៅក្នុងទីធ្លាសាលារៀននេះ។

លោក ស៊ន ប៊ុនឌិន នាយកសាលារៀនបានពោលថា "ខ្ញុំរីករាយណាស់ដែលបានឃើញបន្លែបៃតងនៅក្នុងទីធ្លាសាលា ទឹកមុខញញឹមរបស់សិស្ស និងវឌ្ឍនភាពនៃចំណេះដឹង និងជំនាញរបស់ពួកគេ។"

ម៉ាស៊ីនបូមទឹកមួយដើរដោយថាមពលព្រះអាទិត្យត្រូវបានសាងសង់នៅចុងឆ្នាំ ២០១៤។ វាផ្តល់ប្រយោជន៍ដល់ប្រជាជនចំនួន ៨ គ្រួសារ និងសិស្សចំនួន ២៧១នាក់។ ម៉ាស៊ីនបូមទឹកនេះត្រូវបានសាងសង់ឡើងដើម្បីបង្កើនលទ្ធភាពទទួលបានទឹក និងត្រូវបានប្រើប្រាស់ជាទីលានសម្រាប់ការរៀនសូត្រ ដើម្បីធ្វើឲ្យសិស្សរៀនបានកាន់តែប្រសើរឡើងអំពីផលប៉ះពាល់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ទីនេះក៏ផ្តល់លទ្ធភាពដល់សិស្សក្នុងការទទួលបានបទពិសោធន៍ជាក់ស្តែង អំពីប្រព័ន្ធកសិកម្មចម្រុះផងដែរ។

លោក ប៊ុនឌិន ដែលជានាយកសាលា បានពោលថា ច្បារដំណាំទំហំ ១.៨០០ម៉ែត្រការ៉េនៅក្នុងបរិវេណសាលារៀននេះ ត្រូវបានចែកចេញជាប្រាំផ្នែកសម្រាប់សិស្សពីថ្នាក់ ៣ ដល់ ទី ៦ និងសិស្សរៀនភាសាអង់គ្លេស។ ក្រុមនីមួយៗមកមើលទីតាំងច្បាររបស់ខ្លួននៅពេលព្រឹក មុនម៉ោងចូលរៀន ក្នុងពេលចេញលេង និងនៅក្នុងពេលរសៀល ដើម្បីដាំ និងមើលថែ ព្រមទាំងស្រោចទឹកបន្លែរបស់ពួកគេ។ នេះជាផ្នែកមួយនៃការអភិវឌ្ឍជំនាញរបស់សិស្សក្នុងពេលរៀនផងដែរ។



Photo: Naratevy Kek/UNDP Cambodia

*ក្រុមប្រតិភូមកពីប្រទេសឡាវ កំពុងធ្វើទស្សនកិច្ចក្នុងច្បារដំណាំនៅក្នុងទីធ្លាសាលាបឋមសិក្សា គោកស្រឡៅ ស្ថិតក្នុងខេត្តព្រះវិហារ។ ដោយមានការជ្រោមជ្រែងជាបច្ចេកទេសពីគម្រោងណាប៉ា ទីធ្លាសាលានេះឥឡូវគឺពេញទៅដោយបន្លែបៃតងត្រឹមរយៈពេលតែ១ខែក្រោយមក។*

លោក ហុក គឹមធួន អ្នកគ្រប់គ្រងគម្រោងជាតិ មកពីអង្គភាពគាំទ្រគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានពោលថា "ប្រការសំខាន់គឺត្រូវបញ្ចូលការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងសកម្មភាពតាមសាលារៀន ដើម្បីជួយសិស្សដែលជាមនុស្សជំនាន់ក្រោយរបស់យើងឲ្យយល់ អំពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងយ៉ាងហោចណាស់ត្រៀមខ្លួនជាស្រេចដើម្បីបន្សាំខ្លួនឯង តាមរយៈសកម្មភាពនានា ដូចជាប្រព័ន្ធកសិកម្មចម្រុះនេះជាដើម។"

ក្រសួងនេះបាន និងកំពុងអនុវត្តគម្រោងស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម និងទឹក តាំងពីខែ កញ្ញា ឆ្នាំ ២០១០មកម្លេះ ជាមួយមូលនិធិដែលទទួលបានពីរដ្ឋាភិបាលកាណាដា មូលនិធិបរិស្ថានពិភពលោក យូអិនឌីភី និងវិភាគទានមិនមែនសាច់ប្រាក់ពីរាជរដ្ឋាភិបាលកម្ពុជា។

នៅឆ្នាំ ២០១៤ ស្រះសហគមន៍ចំនួនពីរ ប្រព័ន្ធបូមទឹកដើរដោយថាមពលព្រះអាទិត្យចំនួន ៣៥ និងអណ្តូងស្នប់ចំនួន១៥ត្រូវបានសាងសង់នៅក្នុងភូមិចំនួន ៣៧។ ប្រព័ន្ធទាំងនេះផ្តល់ទឹកដល់ប្រជាជនចំនួន ១.៤៨១ គ្រួសារ ក្នុងនោះ ៦១% នៃអ្នកទទួលផល គឺជាស្ត្រី។

នៅសាលាគោកស្រឡៅ សិស្សដាំបន្លែប្រមាណ ១០ មុខ ដូចជា ត្រកួន សណ្តែកកួរ ត្រសក់ ស្ពៃច្រើនមុខ និងផ្ទី។

យោងតាមលោក ប៊ុនឌិន សួនបន្លែបានផ្តល់ទិន្នផលកើនឡើងចំនួនបីដង បន្ទាប់ពីមានការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធបូមទឹកដើរដោយថាមពលព្រះអាទិត្យ។

បន្លែដែលនៅសេសសល់ពីអាហារពេលព្រឹក ត្រូវបានចែករម្លែកក្នុងចំណោមសិស្សនានា។ សិស្សខ្លះយកចំណែករបស់ខ្លួនទៅផ្ទះ រីឯអ្នកដទៃទៀតលក់បន្លែដែលនៅសល់ទាំងនោះនៅទីផ្សារ។

លោក ប៊ុនឌិន ពោលថា "ប្រាក់ដែលបានពីការលក់បន្លែទាំងនោះមិនច្រើនទេ [ប្រហែល ២,៥ដុល្លាអាមេរិកសម្រាប់ក្រុមនីមួយៗ] ប៉ុន្តែពួកគេរីករាយណាស់ក្នុងការទទួលបានបន្លែ និងបានប្រាក់កាសខ្លះៗដើម្បីទិញសម្ភារៈសិក្សា និងផ្តល់ឲ្យឪពុកម្តាយរបស់ពួកគេ។"

ក្នុងបណ្តាខែខាងមុខនេះមានក្តីរំពឹងថាសិស្សសាលាទាំងនោះ នឹងដាំបន្លែមួយចំនួនដែលអាចទុកបានយូរ ដែលរួមទាំង ត្រប់វែង និងម្ទេសផងដែរ ដែលអាចរក្សាទុកបានរហូតដល់រដូវវស្សា។



Photo: Naratevy Kek/UNDP Cambodia

*កុមារ ងៀន សាវរី អាយុ ១២ឆ្នាំ និងរៀនថ្នាក់ទី៥ កំពុងស្រោចដំណាំនៅក្នុងទីធ្លាសាលាគោកស្រឡៅ ក្នុងខេត្តព្រះវិហារ ក្នុងចន្លោះម៉ោងសិក្សារបស់ខ្លួន។*

# គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុមួយ ផ្តល់ផលបីយ៉ាង



Photo: Chansok Lay/UNDP Cambodia

*កសិករ ភី ហឿន ឱនមើលគ្រាប់ពូជស្រូវដែលគាត់បានព្រួសកាលពីសប្តាហ៍មុន នៅក្នុងស្រែរបស់គាត់ នៅក្នុងភូមិល្វា ឃុំស៊ាង ឃ្វាង ខេត្តព្រៃវែង។*

**ព្រៃវែង** – នៅទីបញ្ចប់ភ្លៀងក៏បានចាប់ផ្តើមធ្លាក់នៅដើមខែឧសភា។ វាបានបន្ធូរក្តីបារម្ភរបស់កសិករ ភី ហឿន ផងដែរបន្ទាប់ពីបានរងចាំទឹកភ្លៀងដើម្បីផ្តល់ជាកំណើតដល់ពូជស្រូវដែលបានព្រួសក្នុងស្រែ កាលពីសប្តាហ៍មុន។

កសិករវ័យ៥២ឆ្នាំរូបនេះបានបង្កើនការធ្វើស្រែរហូតដល់ទៅ៣ដងក្នុង ១ឆ្នាំ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ។ លោកបាន ពោលថា “ឲ្យតែមានភ្លៀងធ្លាក់មកខ្លះៗ ប្រឡាយនឹងចាប់ផ្តើមមានទឹកសម្រាប់ស្រោចស្រពស្រែរបស់ខ្ញុំនៅពេល ដែលវាត្រូវការទឹក”។

នៅឆ្នាំនេះលោកក៏រំពឹងនឹងធ្វើស្រែយ៉ាងហោចណាស់ពីរដងដែរ។ វាគឺជារបៀបធ្វើស្រែថ្មីដែលកសិករនានា បានចាប់ផ្តើមធ្វើបន្ទាប់ពីមានការពង្រីកប្រឡាយដើម្បីបង្កើនលទ្ធភាពស្តុកទឹកដើម្បីស្រោចស្រពវាលស្រែដែលស្ថិតនៅក្នុងឃុំស៊ាង ឃ្វាង ក្នុងខេត្តព្រៃវែង។

លោក សន សាន ដែលជាប្រធានឃុំស៊ាង ឃ្វាង តាំងពីឆ្នាំ២០០២ បានពោលថា “ការធ្វើប្រឡាយហ្នឹងគឺវាត្រូវទៅតាមតម្រូវការដែលយើង និងពួកគាត់បានគិត។ ដោយសារតែការស្តារប្រឡាយ ជីវភាពរបស់ប្រជាជនបានរីកចម្រើនច្រើនដោយសារពួកគាត់អាចធ្វើស្រែយ៉ាងហោចណាស់ពីរដងដែរក្នុង១ឆ្នាំ។ ម៉្យាងទៀតដោយសារទឹកគ្រប់គ្រាន់ទិន្នផលក៏បានកើនឡើងផងដែរពេលប្រមូលផលម្តងៗ។ អញ្ចឹងហើយ ពួកគាត់មានស្រូវគ្រប់គ្រាន់សម្រាប់ក្រុមគ្រួសារ ហើយបានលក់ស្រូវដែលនៅសល់។”

បើទោះបីវាហាក់បីដូចជាដំណោះស្រាយជាទូទៅមួយសម្រាប់ការខ្វះខាតទឹកក៏ដោយ តាមពិតទៅគឺតួនាទីរបស់អាជ្ញាធរមូលដ្ឋានដែលដើរតួនាទីសំខាន់ក្នុងការនាំឲ្យមានការផ្លាស់ប្តូរនេះ។ ដោយមានការទទួលស្គាល់នូវផលប៉ះទង្គិចដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សាឃុំបានបញ្ចូលវិធានការណ៍ពង្រឹង និងបន្សាំនានាទៅនឹងការប្រែប្រួលអាកាសធាតុនេះសម្រាប់សហគមន៍របស់ខ្លួន។

នៅក្នុងឆ្នាំ២០១២ ប្រឡាយមួយខ្សែប្រវែង ២.៤គីឡូម៉ែត្រត្រូវបានស្តារ និងពង្រីកដោយទទួលបានមូលនិធិពីប្រទេសស៊ុយអែដ តាមរយៈគម្រោងរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី)។ ដោយមានមាត់ប្រឡាយទំហំ ៦ម៉ែត្រ និងជម្រៅ ២ម៉ែត្រ ប្រឡាយមួយនេះអាចស្តុកទឹកភ្លៀងគ្រប់គ្រាន់ដើម្បីស្រោចស្រពវាលស្រែប្រមាណ ៩៧០ហិចតា និងយ៉ាងហោចណាស់២ដងក្នុង១ឆ្នាំ។ នៅឆ្នាំបន្តបន្ទាប់មកទៀត ប្រឡាយចំនួន២ខ្សែទៀតដែលមានប្រវែង ៣.៤គីឡូម៉ែត្របន្ថែមទៀតត្រូវបានស្តារ ពង្រីក



Photo: Chansok Lay/UNDP Cambodia

*កសិករ នៅក្នុងភូមិល្វា ឃុំស៊ាង ឃ្វាង ខេត្តព្រៃវែង ចាប់ផ្តើមព្រួសពូជស្រូវ បន្ទាប់ពីមានភ្លៀងធ្លាក់កាលដើមខែឧសភា។*

និងតភ្ជាប់ទៅកាន់បឹងធម្មជាតិមួយ ដើម្បីស្រោចស្រពវាលស្រែប្រមាណជាង១.០០០ហិចតាបន្ថែមទៀតនៅក្នុងឃុំ។ កសិករប្រមាណ១.១៧០គ្រួសារបានទទួលផលប្រយោជន៍ពីការសាងសង់ប្រឡាយទាំងបីខ្សែនេះ ដែលប្រទេសស៊ុយ អែដបានផ្តល់ថវិកាគាំទ្រសរុប ចំនួន១២១.៣១៤ ដុល្លារអាមេរិក។ ក្រុមប្រឹក្សាឃុំក៏បានចូលរួមថវិការចំនួន ២.៧០០ ដុល្លារអាមេរិកដែលដកពីមូលនិធីវិនិយោគរបស់ខ្លួនផងដែល ក្នុងចំណោមប្រភពជំនួយជាថវិការផ្សេងទៀត។

កាលដើមឡើយ ការធ្វើស្រែឲ្យបានផលល្អត្រឹមតែមួយដងក្នុងមួយឆ្នាំ គឺជាអ្វីដែលកសិករក្នុងឃុំនេះប្រាថ្នាចង់បានដោយសារតែការខ្វះខាតទឹក។ ប្រឡាយដែលរត់កាត់វាលស្រែដែលមានស្រាប់មានជម្រៅរាក់ពេកមិនអាចស្តុកទឹកបានដែលធ្វើឲ្យអ្នកភូមិរំពឹងតែលើក្តីអនុគ្រោះពីមេឃ។

មាត់ប្រឡាយក៏ត្រូវបានធ្វើឲ្យធំផងដែរ សម្រាប់អ្នកភូមិអាចធ្វើដំណើរ និងដឹកជញ្ជូនសម្ភារផ្សេងៗផងដែរ។

លោក សែន មាន ដែលជាកសិករអាយុ៤៧ឆ្នាំបានមានប្រសាសន៍ថា “ពីមុនខ្ញុំត្រូវមូរជើងខោដើរក្នុងផុកប្រហែល ៤គីឡូម៉ែត្រ ដោយមានលីស្រូវពូជប្រមាណ ២០ ទៅ ៣០គីឡូក្រាមក្នុង១ជើងៗ មកកាន់ស្រែរបស់ខ្ញុំ។ ខ្ញុំត្រូវលី៥ទៅ៦ជើង ក្នុងពេលព្រួសស្រូវម្តងៗ។ ប៉ុន្តែឥឡូវនេះ ខ្ញុំដឹកតាមរទេះម៉ូតូមកដល់តែម្តង។ វាកាត់បន្ថយពេលវេលាខ្ញុំច្រើនមែនទែន។”

ប្រឡាយទឹកទាំងនោះមិនត្រឹមតែផ្តល់ទឹកឲ្យប្រជាជនសម្រាប់បង្កើនការដាំដុះនោះទេ។ វាក៏ផ្តល់ជាទិន្នផលត្រីដែលជាប្រភពនៃប្រូតេអ៊ីនដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជាផងដែរ។

លោក ឈុំ ឈឿន ដែលជាប្រធានគណៈកម្មាធិការគ្រប់គ្រងទឹកនៅក្នុងភូមិនបានមានប្រសាសន៍ថា “កាលពីឆ្នាំមុន គ្រួសារមួយៗអាចរកត្រីបានប្រហែល៥គីឡូក្រាមពេលមករកត្រីម្តងៗ។ ហើយប្រហែល៣ឬ៤គ្រួសារបានប្រាក់ចំណូលប្រហែល៨០ម៉ឺនរៀលក្នុងមួយគ្រួសារពីការលក់ត្រីក្នុងមួយរដូវ។”

លោកសន សាន ប្រធានឃុំស៊ាង ឃ្វាងបានរំពឹងទុកថាអ្នកភូមិនឹងអាចរកប្រាក់ចំណូលបានកាន់តែច្រើនពីការរកត្រីដោយសារប្រឡាយមួយខ្សែរទៀតទើបត្រូវបានសាងសង់រួច។

ប្រឡាយដែលបានស្តារនិងពង្រីកកាន់តែច្រើនក៏មានន័យថាទឹកគឺកាន់តែសម្បូរសម្រាប់ កសិករដូចរូបលោក ភី ហឿន ក្នុងការបង្កើនការទិន្នផលស្រូវ និងត្រីកាន់តែច្រើនសម្រាប់ប្រជាជនចាប់មកបរិភោគ និងប្រាក់ចំណូលកាន់តែច្រើនសម្រាប់ប្រជាកសិករក្នុងឃុំដើម្បីមកផ្គត់ផ្គង់គ្រួសារ។

លោក ភី ហឿន បានពោលថា “ស្ថានភាពគ្រួសាររបស់ខ្ញុំខុសប្លែក ដូចមេឃ និងដីអញ្ចឹង។ ធ្វើស្រែឥឡូវគឺចំណេញណាស់ឲ្យតែមានទឹកគ្រប់គ្រាន់។ បានលុយហ្នឹងហើយ គ្រាន់ផ្គត់ផ្គង់កូនខ្ញុំពីរនាក់ដែលកំពុងនៅសកលវិទ្យាល័យនៅភ្នំពេញ។”

# កម្ពុជាត្រូវចាប់យកភាគលាភប្រជាសាស្ត្រ ដើម្បីការអភិវឌ្ឍន៍



Photo: Munthit Ker/UNDP Cambodia

*កញ្ញា វិន រតនា, កណ្តាល, កំពុងត្រួតពិនិត្យសហសេវិករបស់នាង នៅយានដ្ឋានរថយន្តមួយដែលនាងគ្រប់គ្រងនៅខេត្តសៀមរាប។ កម្ពុជាត្រូវការកម្មករជំនាញបន្ថែមទៀតដើម្បីសម្រាប់ការលូតលាស់កាន់តែលឿន និងដើម្បីប្រកួតប្រជែងជាមួយប្រទេសជិតខាងជាពិសេសនៅពេលដែលសមាហរណកម្មសេដ្ឋកិច្ចអាស៊ានបានកំពុងខិតចូលមកដល់។*

## ប៉ុន្តែ តើភាគលាភប្រជាសាស្ត្រគឺជាអ្វី?

ភាគលាភ ឬផលចំណេញប្រជាសាស្ត្រ គឺជាកាលៈទេសៈមួយដែលសមាមាត្រភាគច្រើននៃចំនួនប្រជាជនស្ថិតនៅក្នុងវ័យធ្វើការ ធៀបនឹងអត្រាថយចុះនៃចំនួនមនុស្សដែលស្ថិតក្នុងបន្ទុកសរុប។ នេះជាឱកាសប្រកបដោយសក្តានុពលសម្រាប់ប្រទេស ដើម្បីបង្កើនល្បឿនកំណើនសេដ្ឋកិច្ចរបស់ខ្លួនតាមរយៈការវិនិយោគលើវិស័យអប់រំ សុខាភិបាល និងឱកាសផ្នែកខាងសេដ្ឋកិច្ច នៅពេលដែលធនធានកាន់តែសម្បូរ ដោយសារតែការថយចុះនៃអត្រាចំនួនមនុស្សក្នុងបន្ទុក។

## តើវាកើតឡើងដូចម្តេច?

ភាគលាភប្រជាសាស្ត្រផ្តើមកើតឡើងនៅពេលដែលមានការថយចុះនៃអត្រាកំណើត និងអត្រាមរណភាពរបស់កុមារ។ នៅក្នុងដំណាក់កាលនោះ រចនាសម្ព័ន្ធអាយុប្រជាជនផ្តើមប្រែប្រួល ហើយចំនួនប្រជាជនស្ថិតនៅក្នុងវ័យធ្វើការកាន់តែកើនច្រើនឡើង ធៀបនឹងចំនួនមនុស្សស្ថិតក្នុងបន្ទុក។នៅពេលនោះហើយដែលភាគលាភប្រជាសាស្ត្របានកើតឡើង។និយាយម៉្យាងទៀតគឺថាតុល្យភាពនៃអត្រាអ្នកផលិតកាន់តែខ្ពស់ធៀបនឹងតុល្យភាពនៃអត្រាអ្នកប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចមួយ ដែលនាំឲ្យធនធានកាន់តែច្រើនឡើងសម្រាប់ការវិនិយោគលើវិស័យអប់រំ សុខាភិបាល និងសុខុមាលភាពផ្សេងៗទៀត។

## តើអត្ថប្រយោជន៍អ្វីខ្លះកើតចេញពីភាគលាភប្រជាសាស្ត្រ?

នៅពេលអត្រាកំណើតថយចុះ គ្រួសារនានាចាប់ផ្តើមមានកូនក្នុងបន្ទុកកាន់តែតិច។ កំណើននៃអត្រាប្រជាពលរដ្ឋក្នុងវ័យធ្វើការ ធៀបនឹងអត្រាប្រជាជនក្នុងបន្ទុក (កុមារ និងមនុស្សចាស់) បែបនេះអាចផ្តល់ឲ្យប្រទេសមួយនូវសន្ទុះសម្រាប់កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។ នៅពេលមនុស្សធ្វើការកាន់តែច្រើន ពួកគេក៏ផលិតបានកាន់តែច្រើនក្នុងនាមជាប្រទេសមួយ។ មួយវិញទៀត ដោយសារពួកគេអាចវិនិយោគលើការថែទាំសុខភាព និងការអប់រំកូនៗ ដោយពុំចាំបាច់បង្កើនការចំណាយថវិកាចាំបាច់សម្រាប់គ្រួសារដោយសារពួកគេមានកូនតិចជាងធៀបនឹងអ្នកជំនាន់មុន ពួកគេក៏អាចប្រាក់សន្សំកាន់តែច្រើនសម្រាប់ការវិនិយោគទៅអនាគត។



Photo: Chansok Lay/UNDP Cambodia

*កម្មករតោងឡើងបង្គោលអគ្គីសនីក្នុងខេត្តតាកែវដើម្បីតភ្ជាប់ខ្សែរកាប។ កម្មករវ័យក្មេង និងសុខភាពល្អគឺជាឆ្អឹងខ្នងនៃការរីកចម្រើនសេដ្ឋកិច្ច។ យ៉ាងណាក្តី ក្នុងពេលជាមួយគ្នា ប្រទេសកម្ពុជាត្រូវការជំរុញកម្មកររបស់ខ្លួនឲ្យឈានទៅរកជំនាញដែលមានគុណតម្លៃខ្ពស់ ដើម្បីឲ្យប្រទេសទទួលបាននូវផលប្រយោជន៍ច្រើនបំផុតពីភាគលាភប្រជាសាស្ត្ររបស់ខ្លួន។*

ដើម្បីប្រទេសមួយទាញយកផលពីការប្រែប្រួលថ្មីបែបនេះនៃរចនាសម្ព័ន្ធអាយុប្រជាជន ប្រទេសនោះត្រូវធានាថា កម្លាំងពលកម្មយ៉ាងច្រើនរបស់ខ្លួនមានការអប់រំបានល្អ មានជំនាញ និងមានការងារធ្វើដើម្បីទទួលបានផលចំណូល។ ទោះជាយ៉ាងណាក៏ដោយ មានត្រឹមតែកម្លាំងពលកម្មច្រើន មិនមានន័យថាប្រទេសនោះនឹងបានទទួលភាគលាភប្រជាសាស្ត្រឡើយ។ ក្នុងពេលទន្ទឹមគ្នា ប្រទេសនោះត្រូវតែធ្វើការវិនិយោគឲ្យចំគោលដៅក្នុងវិស័យអប់រំ សុខាភិបាល ការបង្កើតការងារ និងអភិបាលកិច្ចល្អ ទើបអាចទទួលបានកំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។

## តើកម្ពុជាអាចទទួលផលពីភាគលាភប្រជាសាស្ត្រដែរឬទេ?

វាអាស្រ័យជាខ្លាំងលើថា តើប្រទេសនេះឆ្លើយតបបានឆាប់រហ័សកម្រិតណាទៅនឹងកត្តាជម្រុញភាគលាភប្រជាសាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ ដំណឹងល្អគឺថាកម្លាំងពលកម្មរបស់កម្ពុជាកំពុងកើនឡើងរហ័សជាងកំណើនចំនួនប្រជាពលរដ្ឋនៃប្រទេសនេះទៅទៀត (២,៧១%ធៀបនឹង១,៦៣%) ដែលផ្តល់នូវភាពធូរស្រាលមួយ ធ្វើយ៉ាងណាឲ្យតែកម្មករមានជំនាញច្បាស់លាស់ ហើយសេដ្ឋកិច្ចគាំទ្រដល់ពួកគេឲ្យមានការងារល្អៗ។ ឥឡូវនេះ កម្ពុជាកំពុងស្ថិតនៅត្រង់ចំណុចកណ្តាលនៃភាគលាភប្រជាសាស្ត្រ ហើយឱកាសនេះនឹងបន្តសម្រាប់រយៈពេល ៣០ឆ្នាំខាងមុខ ឬតិចជាងនេះ។

ដូច្នេះដើម្បីទទួលផលជាអតិប្បរមាពីភាគលាភប្រជាសាស្ត្រ រាជរដ្ឋាភិបាលកម្ពុជាត្រូវបង្កើតបរិយាកាសអំណោយផលសម្រាប់ការវិនិយោគក្នុងប្រទេស និងការវិនិយោគដោយផ្ទាល់ពីបរទេស ព្រមទាំងបង្កើនការវិនិយោគរបស់ខ្លួនលើការអប់រំ សុខភាពសាធារណៈ និងអភិបាលកិច្ចល្អ។ យុទ្ធនាការជាតិក៏មានសារៈសំខាន់ណាស់ដើម្បីលើកទឹកចិត្តឪពុកម្តាយឲ្យគាំទ្រ និងបន្តឲ្យកូនៗទទួលបានការសិក្សា និងសុខភាពល្អ ដោយវិនិយោគលើសុខុមាលភាពនៃកូនៗរបស់ពួកគេ។ ទន្ទឹមនឹងនេះរដ្ឋាភិបាលត្រូវផ្តល់សេវាកម្មសាធារណៈប្រកបដោយគុណភាពនៅក្នុងវិស័យអប់រំ និងសុខាភិបាល។

លោក យឺរ៉ូស បេយេនណេ គឺជាអ្នកសម្របសម្រួលការងាររបាយការណ៍អភិវឌ្ឍន៍មនុស្ស នៅការិយាល័យយូអិនឌីភីប្រចាំប្រទេសកម្ពុជា។



Photo: Thomas Cristofoletti/UNDP Cambodia

*និស្សិតសកលវិទ្យាល័យមួយនៅភ្នំពេញ កំពុងរៀនក្នុងថ្នាក់។ ការធ្វើឲ្យប្រសើរឡើងនូវវិស័យអប់រំ និងជំនាញគឺស្ថិតក្នុងចំណោមជំហានចំបងៗនានាដែលប្រទេសកម្ពុជាត្រូវធ្វើការវិនិយោគបន្ថែម ដើម្បីទទួលបានការរីកចម្រើនសេដ្ឋកិច្ចដ៏លឿនមួយ។*

# សកម្មភាពសម្អាតមីនធ្វើឲ្យក្ដីសង្ឃឹមទទួលបានការសិក្សារបស់ក្មេងមានជីវិតឡើងវិញ



Photo: Chansok Lay/UNDP Cambodia

*សិស្សបឋមសិក្សារ ទំនប់ កំពុងល្បងការគណនាលេខជាមួយមិត្តភក្តិរបស់ខ្លួន។ ប្រសិនបើមិនមានសកម្មភាពសម្អាតមីនទេ សាលាថ្មីមួយនេះ មិនអាចបានលេចចេញជារូបរាងដែរ ហើយក្មេងៗទាំងនេះនឹងត្រូវបង្ខំចិត្តទៅរៀននៅសាលាមួយផ្សេងទៀតដែលនៅឆ្ងាយ ឬត្រូវបោះបង់ចោលការសិក្សា ឬទៅធ្វើការជាមួយឪពុកម្ដាយរបស់ខ្លួន។*

**ប៉ៃលិន** – នៅក្នុងដំណើរការធម្មតាមួយ កុមារី គឹមលាង អាយុ១២ឆ្នាំនេះគួរតែកំពុងរៀនថ្នាក់ទី ៥ ទៅហើយបន្ទាប់ពីបានចូលរៀនថ្នាក់ទី១កាលពី៦ឆ្នាំមុន។ ប៉ុន្តែនាងឥឡូវនេះគឺកំពុងតែរៀនថ្នាក់ទី ៣ គឺមានន័យថានាងបានរៀនយឺតរយៈពេល២ឆ្នាំ។

អ្វីគឺជាបញ្ហា? វាគឺមិនមែនមកពីការរៀនសូត្រមិនពូកែ ឬស្ថានភាពសេដ្ឋកិច្ចក្នុងគ្រួសារដែលរារាំង ការសិក្សារបស់នាងនោះទេ។ បញ្ហាចំបងគឺមកពីគ្រាប់មីន ដែលបន្សល់ទុកមកពីអតីតសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ហើយពួកវានៅតែបន្តរារាំងឱកាសក្នុងការទទួលបានការសិក្សាសមរម្យមួយ និងក្នុងការឈោងចាប់នូវក្តីសុបិន្តរបស់កុមារា កុមារីនានានៅជនបទដូច គឹមលាង ជាដើម។

លោក ទូច ទឹក អនុប្រធានភូមិទំនប់ បានសួរថា "តើយើងអាចអនុញ្ញាតឲ្យមានសាលារៀនម្តេចកើត នៅពេលដែលយើងមិនដឹងថា តើមានគ្រាប់មីន ឬអត់នៅទីកន្លែងនោះ?"

កង្វះខាតសាលារៀននៅជិតផ្ទះនៅពេលនោះតម្រូវឲ្យគឹមលាងធ្វើដំណើរ ១០គីឡូម៉ែត្រទៅ និង ១០គីឡូម៉ែត្រមក ជារៀងរាល់ថ្ងៃ ពីសាលារៀនមួយដែលស្ថិតនៅចុងម្ខាងទៀតនៃភូមិ។ ម្តាយរបស់នាងចង់ឲ្យនាងមានអនាគតខុសប្លែកពីបងៗ។ ប៉ុន្តែ បន្ទាប់ពីរៀនបានរយៈពេល១ឆ្នាំ ការសិក្សារបស់នាងបានជួបឧបសគ្គ។ ដោយសារគ្រួសាររបស់នាងមិនមានមធ្យោបាយធ្វើដំណើរ ម្តាយរបស់នាងបានបង់ប្រាក់ទៅឲ្យបុរសអ្នកជិតខាងម្នាក់ ដើម្បីដឹកនាងតាមទោចក្រយានយន្តរបស់អ្នកជិតខាងនោះ។ ប៉ុន្តែថ្ងៃមួយបុរសនោះបានឈប់បញ្ជូនកូនរបស់ខ្លួនទៅរៀន គឹមលាងក៏ពុំមានវិធីដើម្បីទៅសាលារៀន ដោយខ្លួនឯងផងដែរ។ ការសិក្សារបស់គឹមលាងបានដើរដល់ទីបញ្ចប់។

រឿងរ៉ាវរបស់នាង គឺគ្រាន់តែជារឿងមួយស្ថិតក្នុងចំណោមរឿងស្រដៀងគ្នាជាច្រើនផ្សេងៗទៀតកាលពីមុនរបស់ក្មេងៗដែលរស់នៅក្នុងភូមិទំនប់ ក្នុងខេត្តប៉ៃលិន។ ភាពលំបាកនឹងដំណើរដ៏វែងឆ្ងាយក្នុងការទៅសាលារៀនពីមួយថ្ងៃទៅមួយថ្ងៃបានបង្ខំ ឲ្យក្មេងៗជាច្រើនបោះបង់ចោលការសិក្សា និងស្នាក់នៅផ្ទះ ឬចូលធ្វើការក្នុងចំការដាំដំឡូងមីជាមួយឪពុកម្តាយរបស់ពួកគេ។

ការខ្វះខាតសាលារៀននៅជិត បានក្លាយជាឧបសគ្គក្នុងការសិក្សាមែនហើយ ប៉ុន្តែអ្វីដែលជាប្រភពនៃបញ្ហាគឺគ្រាប់មីនដែលនៅក្នុងដីឯណោះវិញទេ។

ខេត្តប៉ៃលិន គឺជាអតីតទីលានប្រយុទ្ធនៅក្នុងសម័យសង្គ្រាម។ វាក៏ជាខេត្តមួយក្នុងចំណោមខេត្តទាំងបី ដែលកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (យូអិនឌីភី) បានកំពុងធ្វើការជាមួយអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដើម្បីសម្អាតគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ខេត្តពីរផ្សេងទៀតគឺខេត្តបាត់ដំបង និងបន្ទាយមានជ័យ។ គម្រោងបោសសម្អាតមីនដើម្បីលទ្ធផលជំហានទី២ ដែលមានរយៈពេល៥ឆ្នាំ បានទទួលការគាំទ្រផ្នែកថវិកាប្រមាណ ២៦លានដុល្លារអាមេរិច ពីរដ្ឋាភិបាលប្រទេស អូស្ត្រាលី ស្វ៊ីស និងកាណាដា ក្នុងចំណោមប្រទេសផ្សេងៗទៀត។

ចាប់តាំងពីពេលចាប់ផ្តើមក្នុងឆ្នាំ២០១១ គម្រោងនេះបានរំដោះផ្ទៃដីសរុបជិត ៧៣លានម៉ែត្រការ៉េ នៅក្នុងសហគមន៍ជនបទ នៃខេត្តគោលដៅទាំងបី សម្រាប់គោលបំណងអភិវឌ្ឍនានាដូចជា ធ្វើកសិកម្ម សាងសង់សាលារៀន និងផ្លូវថ្នល់ជាដើម។ ដោយឡែកគ្រាន់តែនៅក្នុងខេត្តប៉ៃលិនមួយ ផ្ទៃដីសរុបជិត ១២លានម៉ែត្រការ៉េត្រូវបានសម្អាត និងផ្តល់ជូនឲ្យទៅប្រជាជនប្រើប្រាស់វិញមកទល់នឹងខែមករាឆ្នាំ២០១៥នេះ។



Photo: Chansok Lay/UNDP Cambodia

*ក្មេងៗសិស្សសាលាកំពុងរៀនជាក្រុមនៅក្នុងចន្លោះម៉ោងសិក្សាក្នុងបឋមសិក្សាទំនប់ស្ថិតក្នុងខេត្តប៉ៃលិន។*

នៅក្នុងភូមិទំនប់ ផ្ទៃដី៥១៤.៩៤០ម៉ែត្រការ៉េ ត្រូវបានរំដោះ ហើយមីនប្រឆាំងមនុស្សចំនួន ៧៥គ្រាប់ និងសំណល់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន ១៣១ ត្រូវបានរកឃើញ និងបោសសម្អាត។ ការបោសសម្អាតនេះបានបើកផ្លូវសម្រាប់ការសាងសង់សាលារៀនថ្មីមួយលើផ្ទៃដីទំហំ ២២.២៨២ម៉ែត្រការ៉េ ដែលជាផ្នែកមួយនៃអតីតចំការមីនដែលត្រូវបានរំដោះ និងបើកឲ្យសហគមន៍នេះប្រើប្រាស់នៅក្នុងខែមិថុនា ឆ្នាំ២០១៣ តាមរយៈការសម្របសម្រួលរបស់អង្គភាពរៀបចំផែនការសកម្មភាពមីននៅក្នុងខេត្តនេះ (MAPU)។

ដោយប្រើប្រាស់មូលនិធិរៃអង្គាសបានពីមនុស្ស ៨៥ នាក់ ដែលរួមទាំងអ្នកចម្រៀងខ្មែរមួយចំនួនផងនោះ សាលារៀនមួយខ្នងត្រូវបានសាងសង់ និងបើកទទួលសិស្សឲ្យចូលរៀនក្នុងឆ្នាំសិក្សាថ្មីនៅក្នុងខែតុលា ឆ្នាំ២០១៣។ មុននេះមួយឆ្នាំ ថ្នាក់រៀនបណ្តោះអាសន្នមួយត្រូវបានចាប់ផ្តើមនៅក្រោមសំយ៉ាបផ្ទះរបស់អ្នកភូមិម្នាក់។ សាលារៀនដែលមានបួនបន្ទប់ត្រូវបានឲ្យឈ្មោះដូចភូមិនេះដែរ។ សព្វថ្ងៃនេះសិស្សចំនួន ១១៩នាក់ ក្នុងនោះ ៥៩នាក់ជាកុមារី កំពុងសិក្សាចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៤ ហើយនាយកសាលានេះគ្រោងបន្ថែមថ្នាក់ទី ៥ និងទី ៦ នៅក្នុងបណ្តាឆ្នាំខាងមុខនេះ។

លោក ទូច ទឹក អនុប្រធានភូមិទំនប់ បានពោលថា "ប្រសិនបើគ្មានសកម្មភាពបោសសំអាតគ្រាប់មីនទេនោះ សាលារៀនក៏គ្មាននៅទីនេះដែរ។ សាលារៀននេះអាចចាប់ផ្តើមបានតែនៅពេលដែលយើងប្រាកដថា ដីនៅទីនេះផ្តល់សុវត្ថិភាពគ្រប់គ្រាន់សម្រាប់អគារសិក្សា និងសិស្សតែប៉ុណ្ណោះ។"

អ្នកស្រី អ៊ី អឿន បានពោលថា "ឥឡូវនេះ កូនរបស់ខ្ញុំអាចមកសាលារៀនបានដោយងាយ នឹងជាទៀងទាត់ ដោយសារសាលារៀនស្ថិតនៅជិតផ្ទះរបស់ខ្ញុំ។"

អ្នកស្រីបានពោលបន្តថា "កាលពីមុន កូនខ្ញុំជាញឹកញាប់មិនបានទៅរៀន ដោយសារតែសាលារៀនស្ថិតនៅឆ្ងាយពីផ្ទះ ហើយខ្ញុំពុំមានមធ្យោបាយធ្វើដំណើរសម្រាប់ដឹកពួកគេឡើយ។"

ក្តីសុបិនរបស់ គឹមលាង មានជីវិតឡើងវិញហើយ។ បើទោះបីជានាងត្រូវធ្វើដំណើរវែងឆ្ងាយតទៅទៀតដើម្បីក្លាយទៅជាអ្នកគ្រូពេទ្យម្នាក់ គឹមលាង បាននិយាយថា នាងប្តេជ្ញាចិត្ត ឈានទៅចាប់ក្តីបំណងរបស់នាង។

នាងបាននិយាយថា "ខ្ញុំមិនចង់ដូចឪពុកម្តាយខ្ញុំដែលធ្វើការនៅក្នុងចំការឡើយ។ ការងាររបស់គាត់លំបាកខ្លាំងណាស់។ ខ្ញុំចង់ក្លាយជាគ្រូពេទ្យ ដើម្បីខ្ញុំអាចជួយឪពុកម្តាយខ្ញុំ បងប្អូនខ្ញុំ និងអ្នកភូមិនានា នៅពេលពួកគេឈឺ។"

Empowered lives.
Resilient nations.

អគារលេខ ៥៣ វិថី ប៉ាស្ទ័រ សង្កាត់ បឹងកេងកង១
ប្រអប់សំបុត្រលេខ ៨៧៧ ក្រុងភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ +855 (0) 23 216 167
ទូរសារ ៖ +855 (0) 23 216 257
អ៊ីម៉ែល ៖ registry.kh@undp.org
www.kh.undp.org
www.facebook.com/UNDPCambodia
www.twitter.com/UNDPCambodia